**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ២១៥ សហវ

ភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងភ្នាក់ងារបើកផ្តល់ សំរាប់បើកបៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ

***** *****

**-ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**-ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ . ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ប្រ.ក.ប.ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ក្រ.ក . ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃ គណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វម. ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យ សាធារណៈ

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

# សំ រេ ច

ប្រការ១: ប្រាក់បៀវត្សមន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ត្រូវបើកផ្តល់តាមរយៈ "ភ្នាក់ងារបើកផ្តល់" ។

ប្រការ២: លោក អ៊ុក កាម៉ាច ជាអនុប្រធានការិយាល័យគណនេយ្យ និង ផ្គត់ផ្គង់ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ និង លោក ម៉ែន ស៊ាន ជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ៣: លោក អ៊ុក កាម៉ាច និង លោក ម៉ែន ស៊ាន ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅធនាគារជាតិ ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្ស និងអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ ។

ប្រការ៤: បែបបទនៃការអនុវត្តន៍បើកផ្តល់ប្រាក់បៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ៥: ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និង មូលនិធិ ដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ៦: សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនិងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៧: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានធនាគារជាតិ ព្រមទាំងប្រធាននាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទាំងអស់ និង ក្រុមប្រឹក្សាធម្មនុញ្ញ ព្រមទាំង លោក អ៊ុក កាម៉ាច និងលោក ម៉ែន ស៊ាន ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ០១ ឆ្នាំ ២០០២

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ជិន ឈិន

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ជ.រដ្ឋមន្ត្រីស្តីទី

អ៊ុក រ៉ាប៊ុន

កន្លែងទទួល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ៧

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ